២០-ឧកញ៉ា អ៊ឹង ប៊ុនហួ
២១-ឯកឧត្តម ស៊ុយ សែម
២២-ឯកឧត្តម ជា ចាន់តូ
២៣-លោក យូ គីមឡេង
២៤-លោក ឆេង យីហេង
២៥-លោក ហាក់ ប៊ុនថា
២៦-លោក ឈុន អូន
២៧-លោក ឡោ

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការ កងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យ នេះឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី២១ ខែមេសា ឆ្នាំ២០០០

### សេចក្តីសំរេចលេខ ២៥ សសរ
### ស្តីពីការបង្កើតគណៈកម្មការចំរុះកម្ពុជា សហគមន៍អឺរុប

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០២ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការរវាង ព្រះរាជាណាចក្រកម្ពុជា និងសហគមន៍អឺរុប

- យោងតាមសំណើរបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះ កម្ពុជា សហគមន៍អឺរុប មួយដែលមានសមាសភាពដូចតទៅ :

-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាន

-ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធានទី១

-ឯកឧត្តមរដ្ឋលេខាធិការក្រសួងសុខាភិបាល ជាអនុប្រធានទី២

-ឯកឧត្តម ខុន សំនួន អនុរដ្ឋលេខាធិការក្រសួងការបរទេស ជាអនុប្រធានទី៣

-អ្នកឧត្តម ឈៀង យ៉ាណារ៉ា អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

-តំណាងក្រសួងពាណិជ្ជកម្ម ជាសមាជិក

-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

-តំណាងក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក

-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ ជាសមាជិក

-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

-ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងការបរទេស ទទួលបន្ទុកជាលេខាធិការ

**ប្រការ ២ :** គណៈកម្មការនេះមានបេសកកម្មដូចខាងក្រោម :

-ធ្វើទំនាក់ទំនង និងធ្វើវេទយិតកម្មបញ្ចុះបញ្ចូល សហគមន៍អឺរុប អោយគាំទ្រ និងផ្តល់ជំនួយ សំរាប់ស្តារ និង អភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ច សង្គមកិច្ច សុខាភិបាល អប់រំ វប្បធម៌ កសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ។ល។ នៃព្រះរាជាណាចក្រកម្ពុជា ។

-វាយតំលៃរួមគ្នា អំពីកិច្ចសហប្រតិបត្តិការរៀងរាល់ ០២ ឆ្នាំម្តង ដើម្បីលើកគំរោង និង ទិសដៅសហប្រតិបត្តិការ សំរាប់ឆ្នាំខាងមុខ ។

**ប្រការ ៣ :** ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ចនិងសិទ្ធិ :

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលភាគីទាំងពីរបានឯកភាព ។

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាលដើម្បីស្នើសុំ គោលការណ៍ ឬមតិណែនាំ ។

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។

-មានសិទ្ធិប្រើត្រា នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ភារកិច្ចពាក់ព័ន្ធចាំបាច់ ។

**ប្រការ ៤ :** ត្រូវចាត់ទុកជានិរាករណ៍ សេចក្តីសំរេចលេខ ០៣ សសរ ចុះថ្ងៃទី ២១ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើតគណៈកម្មការចំរុះ កម្ពុជា សហគមន៍អឺរុប ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងសាមីខ្លួនដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# III- ការងារបណ្តាក្រសួង

## ១-ធនាគារជាតិនៃកម្ពុជា

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ២០០០

## ប្រកាស

### ប្រកាសលេខ ធ ៨០០៧៤ ប្រក

### ស្តីពីការវិសោធនកម្មប្រការ ៣០ នៃលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា

****

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៥៤ ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង ឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- បានឃើញប្រកាស ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការធនាគារជាតិនៃកម្ពុជា លេខ ធ៨.៩៩-១២៣ ប្រក ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩
- យោងតាមការអនុមតិរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី០៧ ខែមេសា ឆ្នាំ ២០០០